បានទទួលដំណឹង។ បានចូលរួម។ បានរាប់ចំនួន។

# សៀវភៅណែនាំ ការធ្វើជំរឿនឆ្នាំ2020 របស់អ្នកសម្រាប់អ្នកដែលមានពិការភាព

## ហេតុអ្វីបានជាការធ្វើជំរឿននេះមានសារៈសំខាន់ចំពោះអ្នកដែលរស់នៅជាមួយនឹងពិការភាព?

យោងតាមការប៉ាន់ស្មានចំនួនប្រជាជនឆ្នាំ2018 ដោយក្រសួងជំរឿនសហរដ្ឋអាមេរិកចន្លោះឆ្នាំ2013-2017 បានរាយការណ៍ថា 6.3% នៃពលរដ្ឋរស់នៅទីក្រុង Los Angeles ដែលមានអាយុក្រោម 65 ឆ្នាំ គឺមានពិការភាព។

ជនពិការគថ្លង់ ឬមានការចុះខ្សោយការស្តាប់ ពិការភ្នែក ឬមានការចុះខ្សោយផ្នែកពុទ្ធិ ចាំបាច់ត្រូវបង្ហាញខ្លួន និងត្រូវធ្វើការរាប់ចំនួន។ មនុស្សគ្រប់គ្នាដោយពុំគិតពីពិការភាពនោះទេ នឹងទទួលផលប៉ះពាល់ដោយការរាប់ចំនួននៃការធ្វើជំរឿនដែលមិនត្រឹមត្រូវណាមួយ។ ការផ្តល់មូលនិធិសម្រាប់ការថែទាំសុខភាព កម្មវិធីបណ្តាញសុវត្ថិភាព និងការធ្វើជាតំណាងផ្នែកនយោបាយ នឹងមិនទទួលបានតាមស្តង់ដាកំណត់ឡើយ នៅពេលដែលនរណាម្នាក់មិនចូលរួមនៅក្នុងការធ្វើជំរឿននេះ។

## តើកម្រងសំណួរជំរឿននេះអាចប្រើប្រាស់បានសម្រាប់អ្នកដែលមានវិការៈមួយចំនួនដែរឬទេ?

ជនទាំងឡាយដែលមិនអាចប្រគល់កម្រងសំណងសំណួរតាមអនឡាញ អាចហៅទូរសព្ទតាមខ្សែទូរសព្ទជំរឿនដើម្បីបំពេញកម្រងសំណួរ ឬក៏អាចទទួលបានកម្រងសំណួរជាក្រដាសពីអ្នកធ្វើជំរឿនដើម្បីបំពេញផងដែរ។ ឯករដ្ឋទូតសុឆន្ទៈសម្រាប់ការធ្វើជំរឿនតាមមូលដ្ឋាន និងគណៈកម្មការរាប់ចំនួនពេញលេញ នឹងសហការជាដៃគូផងដែរជាមួយអង្គការនៅតាមសហគមន៍ ដើម្បីព្យាយាមផ្តល់ជំនួយទៅដល់អ្នកដែលអាចមានបញ្ហានិយាយស្តី ភាសាចក្ខុ និងប្រភេទនៃវិការៈផ្សេងទៀត ហើយអាចនឹងត្រូវការជំនួយនៅក្នុងការបំពេញកម្រងសំណួរនេះ។ ម្យ៉ាងទៀតក្រសួងជំរឿន នឹងផ្តល់ សន្ទានុក្រមភាសា និងខ្សែវីដេអូ និងសៀវភៅណែនាំជាអក្សរពុម្ព ដែលមានជាភាសាផ្សេងក្រៅពីភាសាអង់គ្លេសចំនួន 59 ភាសា រួមទាំងភាសាសញ្ញាបែបអាមេរិកាំង អក្សរស្ទាប (Braille) និងអក្សរពុម្ពធំ។

## តើកម្រងសំណួរនេះនឹងអាចស្វែងរកបានសម្រាប់អ្នកដែលមិនចេះនិយាយភាសាអង់គ្លេសដែរឬទេ?

បាទ/ចាស។ តាមអនឡាញ កម្រងសំណួរនេះនឹងមានជាភាសាទាំង 12 នេះ។ អេស្ប៉ាញ ចិន(អក្សរសាមញ្ញ) វៀតណាម កូរ៉េ រុស្ស៊ី អារ៉ាប់ តាកាឡុក ប៉ូឡូញ បារាំង ក្រេអូលីហៃទី ព័រទុយហ្គាល់ និងជប៉ុន។ ខ្សែទូរសព្ទជំរឿនក៏នឹងផ្តល់ជំនួយជាភាសាទាំងនេះ និងឧបករណ៍ទំនាក់ទំនងសម្រាប់មនុស្សគថ្លង់។

កម្រងសំណួរលើក្រដាស នឹងអាចមានជាភាសាអង់គ្លេស និងអេស្ប៉ាញតែប៉ុណ្ណោះ។

ទីក្រុងLos Angeles និងផ្តល់ដំណោះស្រាយ(នានា) យ៉ាងសមស្រប ដើម្បីធានាការប្រើប្រាស់ដោយស្មើភាពគ្នានូវកម្មវិធី សេវាកម្ម និងមន្ទីរវេជ្ជស្ថានរបស់ខ្លួនសម្រាប់មនុស្សដែលមានពិការភាព។ ដើម្បីធ្វើការស្នើសុំ សូមទាក់ទងទៅនាយកដ្ឋានផ្នែកពិការភាពតាមរយៈ DOD.Contact@lacity.org ឬ (213) 202-5668 ជាមុន ក្នុងរយៈពេលប្រាំថ្ងៃធ្វើការឬលើសពីនេះ។

Eric Garcetti @MayorOfLA

census.lacity.org
#2020Census